

# សេរីភាពខាងការ
# បញ្ចេញមតិ


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights


ខែកក្កដា ឆ្នាំ២០២១

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក គឺជាសមាជិកនៃអង្គការផ្លាស់ប្តូរសេរីភាពខាងការបញ្ចេញមតិអន្តរជាតិ (IFEX) ដែលជាបណ្តាញសកលសម្រាប់សេរីភាពខាងការបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃសម្ព័ន្ធពិភពលោកសម្រាប់ការចូលរួមរបស់ពលរដ្ឋ (CIVICUS) ព្រមទាំងជាសមាជិកអង្គការប្រឆាំងទារុណកម្មពិភពលោក ( OMCT SOSTorture Network) និងជាសមាជិក OECD Watch ផងដែរ។

គេហទំព័ររបស់សិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិនិងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គម មកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងផ្លាស់ប្តូរសង្គម នៅសកលវិទ្យាល័យឃ្វីនស្លែនទីក្រុងប្រ៊ីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។

## សេចក្តីថ្លែងអំណរគុណ

ម.ស.ម.ក សូមថ្លែងអំណរគុណចំពោះអង្គការដៃគូ ស្ថាប័នផ្សព្វផ្សាយ និងជាពិសេសយុវជនមកពីមជ្ឈដ្ឋានផ្សេងៗគ្នា ដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុមទាំងផ្ទាល់ និងអនឡាញ និងបានផ្តល់នូវធាតុចូលដ៏មានសារសំខាន់ដើម្បីកំណត់នូវប្រធានបទទាក់ទងនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។

## អំពីមេរៀនស្តីពីសេរីភាពខាងការបញ្ចេញមតិ

មេរៀនស្តីពីសេរីភាពខាងការបញ្ចេញមតិ ("មេរៀន") តាក់តែងឡើងជាផ្នែកមួយនៃគម្រោងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា ក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងដល់ពលរដ្ឋអំពី សិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅប្រទេសកម្ពុជា។ មេរៀននេះនឹងលើកឡើងនូវនិយមន័យនៃសេរីភាពខាងការបញ្ចេញមតិ ក្របខ័ណ្ឌច្បាប់ដែលត្រូវអនុវត្ត និងកាតព្វកិច្ចរបស់រដ្ឋក្នុងការលើកកម្ពស់សិទ្ធិរបស់បុគ្គលគ្រប់រូបចំពោះសេរីភាពខាងការបញ្ចេញមតិផងដែរ។

ជាមួយគ្នានេះដែរមេរៀននេះ ក៏ផ្តល់នូវការពន្យល់យ៉ាងទូលំទូលាយអំពីរបៀបដែលសិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវបានការពារដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីបង្ហាញនិងមានផ្តល់នូវឧទាហរណ៍ជាក់ស្តែងសម្រាប់អ្នកអានពីសិទ្ធិនេះផងដែរ។

## ចម្ងល់ និងមតិរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមទាក់ទងនឹងមេរៀននេះ សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈ៖

អាសយដ្ឋាន៖ផ្ទះ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ +៨៥៥ (០) ២៣ ៧២ ៦៩ ០១

គេហទំព័រ៖ www.cchrcambodia.org

cc BY NC SA

# មាតិកា

១. សេចក្តីផ្តើម ........ ១
២. តើអ្វីទៅជាសេរីភាពខាងការបញ្ចេញមតិ? ........ ១
៣. ក្របខណ្ឌច្បាប់ចំពោះសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ........ ២
៤. កាតព្វកិច្ចរដ្ឋចំពោះសេរីភាពខាងការបញ្ចេញមតិ ........ ៣
៤.១. កាតព្វកិច្ចគោរព ........ ៣
៤.២. កាតព្វកិច្ចការពារ ........ ៣
៤.៣. កាតព្វកិច្ចបំពេញ ........ ៤
៥. ការរឹតត្បិតចំពោះសេរីភាពខាងការបញ្ចេញមតិ ........ ៤
៥.១. ការអនុញ្ញាតដល់ការរឹតត្បិតដោយច្បាប់ ........ ៥
៥.២. គោលបំណងស្របច្បាប់ ........ ៥
៥.៣. ភាពចាំបាច់ និងសមាមាត្រ ........ ៦

# សេរីភាពខាងការបញ្ចេញមតិ

## ១. សេចក្តីផ្តើម

សេរីភាពខាងការបញ្ចេញមតិ គឺជាគុណតម្លៃស្នូលមួយនៃដំណើរការប្រជាធិបតេយ្យ។ សេរីភាពខាងការបញ្ចេញមតិធានាពលរដ្ឋអាចពិភាក្សា ផ្លាស់ប្តូរគំនិត ជជែកវែកញែកទៅលើគំនិតក៏ដូចជាការទទួលព័ត៌មាន និងការចែករំលែកជាមួយអ្នកដ៏ទៃដោយពុំមានការគាបសង្កត់ ឬព្យាបាទ។ សេរីភាពខាងការបញ្ចេញមតិមិនត្រឹមតែជាសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែបានដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារនូវសិទ្ធិផ្សេងៗទៀត។ សេរីភាពមួយនេះក៏ជាលក្ខខណ្ឌចាំបាច់មួយសម្រាប់តម្លាភាព និងគណនេយ្យភាពដែលជាកត្តាចាំបាច់ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស នីតិរដ្ឋ និងប្រជាធិបតេយ្យ។[1]



## ២. តើអ្វីទៅជាសេរីភាពខាងការបញ្ចេញមតិ?

សេរីភាពខាងការបញ្ចេញមតិត្រូវបានកំណត់ដោយច្បាប់អន្តរជាតិ ថាជាសិទ្ធិក្នុងការប្រកាន់យកមតិយោបល់ដោយគ្មានការជ្រៀតជ្រែកហើយមិនត្រឹមតែប៉ុណ្ណោះ ពលរដ្ឋក៏មានសិទ្ធិក្នុងការស្វែងរក ទទួល និងចែកចាយព័ត៌មានឬគំនិតគ្រប់បែបយ៉ាង ដោយមិនគិតពីព្រំដែន និងមិនថាតាមមធ្យោបាយណាមួយឡើយទោះតាមរយៈផ្ទាល់មាត់ក្តី ការសរសេរ ឬបោះពុម្ពក្តីក្នុងទម្រង់សិល្បៈឬតាម

[1] សេចក្តីពន្យល់ទូទៅលេខ ៣៤ ទៅលើមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិរបស់គណៈកម្មាការសិទ្ធិមនុស្ស អ.ស.ប លើកទី ១០២ ខែកក្កដា ឆ្នាំ ២០១១ ទំព័រទី ១

រយៈប្រព័ន្ធផ្សព្វផ្សាយណាមួយក៏ដោយ។ សិទ្ធិសេរីភាពខាងការញ្ចេញមតិគឺរួមបញ្ចូលទាំងសេរីភាពនៃគំនិតសេរីភាពសារព័ត៌មាននិងសិទ្ធិទទួលព័ត៌មាន។









## ៣. ក្របខណ្ឌច្បាប់ចំពោះសិទ្ធិសេរីភាពខាងការបញ្ចេញមតិ

ក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា បញ្ចូលនូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិទៅនឹងច្បាប់ជាតិ។ ដូច្នេះសិទ្ធិសេរីភាពខាងការបញ្ចេញមតិគឺត្រូវបានការពារដោយច្បាប់ជាតិ និងច្បាប់អន្តរជាតិ។[2]

ក្នុងមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញចែងថា "ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និង ដល់សន្តិសុខជាតិបានឡើយ។[3]

ដូចគ្នានេះដែរ មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការមានមតិ និងការសម្តែងមតិ។ សិទ្ធិនេះ រាប់បញ្ចូលទាំង សេរីភាពក្នុងការប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរក ការទទួល និងការផ្សព្វផ្សាយព័ត៌មាននិងគំនិតនានាដោយគ្មានព្រំដែនទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ"។[4] មាត្រា១៩ កថាខណ្ឌទី២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយចែងថា "ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះត្រូវរាប់បញ្ចូលទាំងសេរីភាពស្វែងរក ទទួល

[2] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[3] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[4] មាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាង ដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ សរសេរ ឬបោះពុម្ព តាមទម្រង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន។”[5]

## ៤. កាតព្វកិច្ចរដ្ឋចំពោះសេរីភាពខាងការបញ្ចេញមតិ

រដ្ឋមានកាតព្វកិច្ចក្នុងការលើកស្ទួយសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលមានសមាសធាតុបីគឺ ៖ គោរព ការពារ និងបំពេញ។




### ៤.១. កាតព្វកិច្ចគោរព

“កាតព្វកិច្ចគោរព” មានន័យថារដ្ឋភាគីមានកាតព្វកិច្ចត្រូវទប់ស្កាត់ពីការរារាំងដល់ការទទួលបានសេរីភាពខាងការបញ្ចេញមតិដោយបុគ្គល ឬក្រុមណាមួយ។ កាតព្វកិច្ចនេះហាមប្រាមសកម្មភាពខ្លះៗ ពីសំណាក់រដ្ឋាភិបាលដែលអាចធ្វើឱ្យខូចខាតដល់ការទទួលបាននូវសេរីភាពនេះ។[6] ឧទាហរណ៍ រដ្ឋមិនគួរអនុម័តច្បាប់ដែលមានការហាមឃាត់រាល់សេរីភាពខាងការបញ្ចេញមតិមិនថាតាមរយៈទម្រង់ណាក៏ដោយ លើកលែងតែមានការលើកលែងដែលបានបញ្ជាក់ (សូមមើលបន្ថែមនៅផ្នែកទី ៥) ព្រោះទង្វើទាំងនេះជាការរំលោភលើកាតព្វកិច្ចរបស់រដ្ឋ ចំពោះការគោរពនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

### ៤.២. កាតព្វកិច្ចការពារ

“កាតព្វកិច្ចការពារ” តម្រូវឱ្យរដ្ឋការពារបុគ្គលទាំងឡាយប្រឆាំងនឹងការរំលោភបំពានពីតួអង្គមិនមែនរដ្ឋ ភ្នាក់ងារបរទេស ឬភ្នាក់ងាររដ្ឋដែលធ្វើសកម្មភាពខុសពីសមត្ថភាពផ្លូវការរបស់ខ្លួន។ រដ្ឋមានកាតព្វកិច្ចតាក់តែងច្បាប់ ដើម្បីការពារសេរីភាពខាងការបញ្ចេញមតិ ចាត់វិធានការដើម្បីការពារបុគ្គល

[5] មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[6] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ ទំព័រទី ៣៤ (២០១៦)

នៅពេលដែលខ្លួនដឹង (ឬអាចនឹងដឹង) ពីការគំរាមកំហែងដល់សេរីភាពនេះ និងធានាចំពោះការទទួលបាននូវភាពយុត្តិធម៌ នៅពេលដែលមានការរំលោភបំពានសេរីភាពខាងការបញ្ចេញមតិត្រូវបានចោទប្រកាន់។[7] ជាឧទាហរណ៍ ប្រសិនបើអ្នកកាសែតត្រូវបានវាយប្រហារដោយឈ្មួញឈើ បន្ទាប់ពីគាត់បានសរសេរអត្ថបទស្តីពីការកាប់ឈើខុសច្បាប់ នោះរដ្ឋមានតួនាទីការពារដល់អ្នកកាសែត ដោយផ្តន្ទាទោសទៅលើឈ្មួញឈើចំពោះការវាយប្រហាររបស់ខ្លួនទៅលើអ្នកកាសែត ដែលបានអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់គាត់។ រដ្ឋមានទំនួលខុសត្រូវក្នុងការចាត់វិធានការសមស្របណាមួយដើម្បីការពារសិទ្ធិរបស់អ្នកសារព័ត៌មាន។

### ៤.៣. កាតព្វកិច្ចបំពេញ

នៅក្រោម "កាតព្វកិច្ចបំពេញ" រដ្ឋត្រូវចាត់វិធានការដើម្បីធានាឱ្យបាននូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិជាពិសេសដើម្បីបញ្ចូលសិទ្ធិសេរីភាពខាងការបញ្ចេញមតិទៅក្នុងច្បាប់ជាតិ និងធានានូវការទទួលបានសេរីភាពខាងការបញ្ចេញមតិនេះពេញលេញ។ រដ្ឋគួរតែបង្កើតលក្ខខណ្ឌច្បាប់ ស្ថាប័ន និងនីតិវិធីសម្រាប់តម្រូវការរបស់អ្នកកាន់កាប់សិទ្ធិ ដើម្បីសម្រេចសិទ្ធិរបស់ពួកគេ និងចូលរួមពេញលេញចំពោះសិទ្ធិរបស់ខ្លួន។[8]

## ៥. ការរឹតត្បិតចំពោះសេរីភាពខាងការបញ្ចេញមតិ

មាត្រា១៩ កថាខណ្ឌទី ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុញ្ញាតឱ្យមានការរឹតត្បិតទៅលើសេរីភាពខាងការបញ្ចេញមតិ។ ដើម្បីអាចអនុញ្ញាតបានតាមច្បាប់អន្តរជាតិ ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិ ត្រូវតែមានភាពតឹងរ៉ឹងនិងតូចចង្អៀតបំផុត ហើយមិនបង្កនូវភាពអវិជ្ជមានដល់សិទ្ធិនេះឡើយ។ ដើម្បីកំណត់ថាតើការរឹតត្បិតអាចអនុញ្ញាតបានគឺត្រូវមើលទៅលើការធ្វើការថ្លឹងថ្លែងទាំងបីផ្នែកនេះ៖ ការរឹតត្បិតត្រូវតែ



[7] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ ទំព័រទី ៣៤ (២០១៦)

[8] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, កូនសៀវភៅសម្រាប់អ្នកតំណាងរាស្ត្រ ទំព័រទី ៣៤ (២០១៦)

(ក) ការអនុញ្ញាតដល់ការរឹតត្បិតដោយច្បាប់ (ខ) មានគោលបំណងស្របច្បាប់ និង(គ) អនុលោមទៅនឹងការវាយតម្លៃដ៏តឹងរ៉ឹងនៃភាពចាំបាច់និងសមាមាត្រ។

### ៥.១. ការអនុញ្ញាតដល់ការរឹតត្បិតដោយច្បាប់



មាត្រា ១៩ កថាខណ្ឌទី ៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតម្រូវឱ្យមានការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិត្រូវតែផ្តល់ដោយច្បាប់។ ជាពិសេសច្បាប់ត្រូវតែមានភាពច្បាស់លាស់ ដើម្បីឱ្យបុគ្គលម្នាក់ៗអាចគ្រប់គ្រងដល់ការប្រព្រឹត្តរបស់ខ្លួនបាន។ ដូច្នេះការរឹតត្បិតដែលមិនមានភាពច្បាស់លាស់ ឬទូលំទូលាយពេកលើសេរីភាពខាងការបញ្ចេញមតិ គឺមិនត្រូវបានអនុញ្ញាតឡើយ។ ក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយផ្ទាល់ក៏បានផ្តល់នូវការរឹតត្បិតផ្នែកច្បាប់ចំនួនពីរចំពោះសេរីភាពខាងការបញ្ចេញមតិនៅក្នុងមាត្រា ២០ ដោយហាមឃាត់ការឃោសនាឱ្យមានសង្គ្រាម និងការអំពាវនាវណាឱ្យមានការស្អប់ខ្ពើមជាតិ ពូជសាសន៍ ឬសាសនាដែលជាការញុះញង់នាំឱ្យកើតមានការរើសអើង ការប្រទូសរ៉ាយ ឬអំពើហិង្សា។[9]

### ៥.២. គោលបំណងស្របច្បាប់

ការរារាំងទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ត្រូវតែគោរពតាមគោលបំណងស្របច្បាប់ដែលមានចែងក្នុងមាត្រា១៩ កថាខណ្ឌទី៣ កថាខណ្ឌរង ក និង ខ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ គោលបំណងតែមួយគត់ដែលអាចត្រូវបានសំអាងថាស្របច្បាប់ក្នុងការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិគឺ ៖ ១) គោរពសិទ្ធិ និងកិត្តិយសរបស់អ្នកដទៃ និង ២) ការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខភាពសាធារណៈឬសីលធម៌។ ដូច្នេះរដ្ឋមិនអាចហាមឃាត់ព័ត៌មានដោយផ្អែកលើមូលដ្ឋានដែលពលរដ្ឋបង្ហាញទស្សនៈរិះគន់ដល់រដ្ឋាភិបាលនោះទេ ដោយការរឹតត្បិតបែបនេះមិនគោរពតាមគោលបំណងស្របច្បាប់ណាមួយដែលមានចែងក្នុងមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ។ ស្រដៀងគ្នានេះដែរ ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិមិនអាចជាលេសសម្រាប់ការពាររដ្ឋាភិបាលពីការអាម៉ាស់មុខ ឬការលាតត្រដាងពី សកម្មភាពខុសច្បាប់ ឬដើម្បីលាក់ព័ត៌មានអំពីមុខងារនៃស្ថាប័នសាធារណៈរបស់រដ្ឋាភិបាលឡើយ។

---

[9] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ២០

## ៥.៣. ភាពចាំបាច់ និងសមាមាត្រ

ភាគីរដ្ឋនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមានកាតព្វកិច្ចធានាថា ការរឹតត្បិតស្របច្បាប់ណាមួយលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ គឺមានភាពចាំបាច់និងសមាមាត្រ។ រដ្ឋត្រូវតែបង្ហាញការផ្សារភ្ជាប់ដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិដែលខ្លួនចង់រឹតត្បិត និងផលប្រយោជន៍នៃការការពារ។ សមាមាត្រ មានន័យថាជាវិធានការរឹតត្បិតតិចតួចបំផុត ដែលត្រូវបានអនុវត្តប្រសិនបើការរឹតត្បិតអាចឆ្លើយតបគោលបំណងដូចគ្នាទៅនឹងវិធានការរឹតត្បិតជាងនេះ។



**ឧទាហរណ៍៖** ប្រសិនបើរដ្ឋចង់អោយព័ត៌មានពីគេហទំព័រត្រូវបានលុបចោល រដ្ឋត្រូវបង្ហាញថាការរឹតត្បិតនេះ គឺចាំបាច់ដើម្បីឆ្លើយតបនឹងគោលបំណងមួយក្នុងចំណោមគោលបំណងស្របច្បាប់ ដែលមានចែងក្នុងមាត្រា ១៩ ហើយដោយមានសមាមាត្រ នោះមានន័យថាការរឹតត្បិតនេះជាវិធានការដែលមានការរឹតត្បិតតិចតួចបំផុត។ ខណៈពេលដែលការបិទគេហទំព័រអាចនឹងឆ្លើយតបគោលបំណងស្របច្បាប់ តែការបិទគេហទំព័រមិនមែនជាការរឹតត្បិត ដែលអាចអនុញ្ញាតបានទេ ព្រោះមិនមែនជាការឆ្លើយតបដែលសមាមាត្រ។ ជាការពិតមានវិធានការរឹតត្បិតតិចតួចជាងនេះ ដែលអាចប្រើប្រាស់បានដូចជាការលុបទំព័រជាក់លាក់ណាមួយនៅលើគេហទំព័រជាជាងបិទគេហទំព័រទាំងមូល៕

----ចប់----